ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
គណៈកម្មាធិការលទ្ធកម្ម
លេខ :..០៤៦....បទ.គល

រាជធានីភ្នំពេញ, ថ្ងៃ ១៤ ខែ មីនា ឆ្នាំ២០១៧

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់ បម្រើការងាររដ្ឋបាល និងសេវាកម្មក្នុងឆមាសទី១ ឆ្នាំ២០១៧

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងចំពោះបណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកតបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់បម្រើការងាររដ្ឋបាល និងសេវាកម្មក្នុងឆមាសទី១ ឆ្នាំ២០១៧។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំសំណើដេញថ្លៃសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញសម្រាប់ចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានអាសយដ្ឋានអគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី.០៩.. ខែមេសា...ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ(ទូរសព្ទទាក់ទងលេខ ០២៣ ៤២៧ ៥០៧)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១៤:០០រសៀល ថ្ងៃទី.០៩... ខែឧសភា.ឆ្នាំ២០១៧។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៤:០០.... រសៀល ថ្ងៃទី..០៩.. ខែឧសភា ឆ្នាំ២០១៧។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មសម្រាប់ទិញសំណើដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម
អនុប្រធានទី១

សាវ៉ាត់ ខាន់

ចម្លងជូន ÷
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកសារ កាលប្បវត្តិ

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ(៨៥៥) ២៣-៤២៧៥០៧
E-mail : mptc.pu@gmail.com